# សហគមន៍ខ្មែរក្រោមគ្រោងស្នើដាក់បញ្ចូលប្រវត្តិសាស្ត្រកម្ពុជាក្រោមក្នុងកម្មវិធីសិក្សា

*ប្រភពព័ត៌មាន វិទ្យុអាស៊ីសេរី ដោយ យាង សុជាមេត្តា  ថ្ងៃទី០១ ខែតុលា ព.ស.២៥៥៩ គ.ស.២០១៥*

សហគមន៍ខ្មែរកម្ពុជាក្រោម គ្រោងស្នើក្រសួងអប់រំ យុវជន និងកីឡា ដាក់បញ្ចូលប្រវត្តិសាស្ត្រកម្ពុជាក្រោម ទៅក្នុងកម្មវិធីសិក្សារបស់រដ្ឋ។ គម្រោងនេះ ធ្វើឡើងបន្ទាប់ពីសហគមន៍ខ្មែរកម្ពុជាក្រោម បានបញ្ចប់បេសកកម្មស្វែងរកឯកសារកម្ពុជាក្រោមជាលើកទី២ នៅប្រទេសបារាំង ដើម្បីយកមកធ្វើជាឯកសារ និងដើម្បីបង្ហាញរដ្ឋាភិបាលវៀតណាម ដែលកន្លងមកបានអះអាងថា ទឹកដីកម្ពុជាក្រោម មិនមែនជាទឹកដីរបស់ខ្មែរ ដែលបារាំង កាត់ទៅឲ្យប្រទេសវៀតណាម គ្រប់គ្រងនោះទេ តែវាជារបស់ប្រទេសវៀតណាម តាំងពីយូរយារណាស់មកហើយ។

សហគមន៍ខ្មែរកម្ពុជាក្រោម យល់ឃើញថា ឯកសារប្រវត្តិសាស្ត្រពាក់ព័ន្ធទៅនឹងដែនដីកម្ពុជាក្រោម ដែលពួកគេបានរកឃើញនៅប្រទេសបារាំង កាលពីពេលថ្មីៗនេះ នឹងរួមចំណែកធ្វើឲ្យកូនខ្មែរយល់កាន់តែច្រើនថែមទៀតអំពីទឹកដីកម្ពុជាក្រោម ដែលបាត់បង់ទៅក្នុងកណ្ដាប់ដៃរបស់ប្រទេសវៀតណាម។

ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោម លោក ថាច់ សេដ្ឋា ដែលកន្លងមកបានដឹកនាំខ្មែរក្រោម យុវជននិងពលរដ្ឋខ្មែរធ្វើបាតុកម្មទាមទារឲ្យរដ្ឋាភិបាលវៀតណាម ទទួលស្គាល់ប្រវត្តិសាស្ត្រទឹកដីកម្ពុជាក្រោម ពេលនេះលោកបានបញ្ចប់បេសកកម្មស្វែងរកឯកសារជាលើកទី២ របស់លោកពីប្រទេសបារាំង រួចហើយ។

លោក ថាច់ សេដ្ឋា ឲ្យដឹងកាលពីថ្ងៃទី២៧ ខែកញ្ញា ថា ឯកសារដែលលោកស្វែងរកបានពីប្រទេសបារាំង មានទាំងអស់ជាង ៣ពាន់ទំព័រ ចំណែកផែនទីវិញមាន ២៧៥ផ្ទាំង។ លោកថា ឯកសារ និងផែនទីទាំងអស់នោះ គឺទាក់ទងទៅនឹងរឿងរ៉ាវដែលកើតមាននៅលើទឹកដែនដីកម្ពុជាក្រោម ក្នុងសម័យបារាំង គ្រប់គ្រង ជាពិសេស គឺសន្ធិសញ្ញា និងឯកសារពាក់ព័ន្ធនានារវាងបារាំង និងវៀតណាម ក្នុងការកាត់ទឹកដីកម្ពុជាក្រោម ទៅឲ្យវៀតណាមគ្រប់គ្រង។




ប្រធានសមាគមខ្មែរកម្ពុជាក្រោម លោក ថាច់ សេដ្ឋា ថ្លែងក្នុងពិធីខួប ៦៤ឆ្នាំ ថ្ងៃអាណានិគមនិយមបារាំង កាត់ទឹកដីខ្មែរឲ្យវៀតណាម នាខណ្ឌសែនសុខ រាជធានីភ្នំពេញ នៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៣។

លោក ថាច់ សេដ្ឋា ឲ្យដឹងដែរថា ក្រៅពីផែនទី និងឯកសារអំពីកម្ពុជាក្រោម ក្រុមការងាររបស់លោកក៏បានរកឃើញឯកសារ និងផែនទីរបស់ប្រទេសកម្ពុជា ផងដែរ។ យ៉ាងណា លោកថា ឯកសារ និងផែនទីទាំងអស់នេះមួយចំនួនបានដល់ដៃរបស់ក្រុមលោករួចហើយ។ ចំណែកឯកសារសេសសល់ ក្រុមលោកកំពុងឲ្យគេថតចម្លង និងអាចបញ្ជូនមកកម្ពុជា នៅចុងខែតុលា។

យ៉ាងណា លោក ថាច់ សេដ្ឋា ថ្លែងថា ឯកសារ និងផែនទីដែលក្រុមការងារលោករកបាននេះ គឺមិនមែនសម្រាប់យកមកផ្ទៀងផ្ទាត់ជាមួយផែនទីរបស់រដ្ឋាភិបាលអ្វីនោះឡើយ តែសម្រាប់ធ្វើជាឯកសារយោងបម្រើដល់ការសិក្សាស្រាវជ្រាវជាទូទៅរបស់សិស្ស និស្សិត និងអ្នកស្រាវជ្រាវអំពីប្រវត្តិសាស្ត្រទឹកដីកម្ពុជាក្រោម ប៉ុណ្ណោះ។

លោកថា ក្រុមការងារលោកកំពុងបកប្រែឯកសារទាំងអស់នេះទៅជាភាសាខ្មែរ រួចបោះពុម្ពជាសៀវភៅចែកចាយដោយឥតគិតថ្លៃទៅដល់ពលរដ្ឋខ្មែរ សិស្ស និស្សិត ឬអ្នកស្រាវជ្រាវ ទៅតាមលទ្ធភាពថវិកាដែលមាន។ ក្រុមលោកក៏គ្រោងយកឯកសារទាំងនេះទៅតម្កល់ទុកនៅរាជបណ្ឌិត្យសភាកម្ពុជា ផងដែរ។ លើសពីនេះលោកថា លោកក៏គ្រោងនឹងស្នើទៅកាន់ក្រសួងអប់រំ យុវជន និងកីឡា ដាក់បញ្ចូលប្រវត្តិសាស្ត្រដែនដីកម្ពុជាក្រោម ទៅក្នុងកម្មវិធីសិក្សារបស់រដ្ឋដែរ៖ «ខ្ញុំចង់ស្នើគេឲ្យបញ្ចូលក្នុងកម្មវិធីសិក្សាផ្នែកប្រវត្តិសាស្ត្រឲ្យសិស្ស និស្សិតបានដឹងពីប្រវត្តិសាស្ត្រក្នុងប្រទេសរបស់ខ្លួនពីអតីតកាល បច្ចុប្បន្ន ការបាត់បង់ហូរហែ ពីព្រោះប្រទេសជិតខាងគេរៀនរហូតរហូតដល់គេបំភ្លៃប្រវត្តិសាស្ត្រ គេថារបស់គេ រឿងអីទឹកដីរបស់យើង យើងមិនខំប្រឹងរៀន ខំបណ្ដុះបណ្ដាលឲ្យយុវជន សិស្ស និស្សិត ឲ្យយល់ពីប្រវត្តិសាស្ត្ររបស់ខ្លួន។ យើងនាំគ្នាទៅកាយកប់រហូត។ ដូច្នេះហើយខ្ញុំយល់ថាការដាក់ចូលទៅក្រសួងអប់រំ គឺមានសារសំខាន់ណាស់ បើសិនណាខាងរដ្ឋាភិបាលគិតថាជាប្រយោជន៍ដ៏ធំសម្រាប់ជាតិរបស់ខ្លួនឯង សម្រាប់យុវជន សិស្ស និស្សិត ស្វែងយល់ពីប្រវត្តិសាស្ត្រខ្លួនឯង»។

ដែនដីកម្ពុជាក្រោម ត្រូវបានអាណានិគមបារាំង គ្រប់គ្រងចាប់តាំងពីឆ្នាំ១៨៥៩។ រហូតដល់ថ្ងៃទី៤ ខែមិថុនា ឆ្នាំ១៩៤៩ បារាំង បានកាត់ទឹកដីនេះទៅឲ្យស្ដេចវៀតណាម បាវ ដាយ (Bao Dai) គ្រប់គ្រង ដើម្បីជាថ្នូរយកកម្លាំងរបស់ស្ដេច បាវ ដាយ ទៅទប់ទល់នឹងកម្លាំងកុម្មុយនីស្តរបស់ លោក ហូ ជីមិញ (Ho Chi Minh)។ ការកាត់ទឹកដីកម្ពុជាក្រោម ទៅឲ្យវៀតណាម គ្រប់គ្រងនេះ បារាំង មិនបានឲ្យពលរដ្ឋខ្មែរជាម្ចាស់ស្រុកបានដឹងឡើយ។

បើទោះជាបែបនេះក្ដី រដ្ឋាភិបាលវៀតណាម កាលពីខែមិថុនា ឆ្នាំ២០១៤ បានថ្លែងថា ទឹកដីកម្ពុជាក្រោម មិនមែនបារាំង កាត់ឲ្យវៀតណាម គ្រប់គ្រងបន្តនោះទេ ប៉ុន្តែវាជាទឹកដីរបស់វៀតណាម តាំងពីយូរយារមកហើយ។ ការថ្លែងរបស់រដ្ឋាភិបាលវៀតណាម នេះ បានធ្វើឲ្យខ្មែរក្រោម និងពលរដ្ឋខ្មែរខឹងសម្បារជាខ្លាំង ហើយបាននាំគ្នាធ្វើ

បាតុកម្មទាមទារឲ្យរដ្ឋាភិបាលវៀតណាម ទទួលស្គាល់ប្រវត្តិសាស្ត្រទឹកដីកម្ពុជាក្រោម រហូតដល់មានការដុតកម្ទេចទង់ជាតិវៀតណាម មួយចំនួនផង។

ដំណើរស្វែងរកឯកសាររបស់សហគមន៍ខ្មែរកម្ពុជាក្រោម ពេលនេះ ក៏ជាផ្នែកមួយនៃបេសកកម្មរបស់ខ្មែរក្រោម ក្នុងការបញ្ជាក់ឲ្យរដ្ឋាភិបាលវៀតណាម ដឹងថា ទឹកដីកម្ពុជាក្រោម មិនមែនជារបស់វៀតណាម តាំងពីយូរណាស់មកហើយនោះទេ ប៉ុន្តែវាជាអតីតទឹកដីរបស់កម្ពុជា។

ខ្មែរក្រោមតវ៉ា ៦២០

ក្បួនហែរបស់បាតុករខ្មែរក្រោមទាមទារឲ្យវៀតណាម សុំទោសជាសាធារណៈរឿងបំភ្លៃប្រវត្តិសាស្ត្រទឹកដីកម្ពុជាក្រោម កាលពីថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៤។ RFA/Ouk Savborey

អ្នកស្រាវជ្រាវប្រវត្តិសាស្ត្រនយោបាយ និងជាអនុប្រធានវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិ នៃរាជបណ្ឌិត្យសភាកម្ពុជា លោកបណ្ឌិត សុខ ទូច មានប្រសាសន៍ថា លោកសាទរចំពោះការស្រាវជ្រាវរបស់ខ្មែរក្រោមនេះ។ លោកបណ្ឌិត សុខ ទូច ដែលថ្លែងចាត់ទុកឯកសារប្រវត្តិសាស្ត្រថាមានតម្លៃសម្រាប់ការសិក្សាស្រាវជ្រាវនោះ លោកមានប្រសាសន៍ថា លោករីករាយនឹងទទួលយកឯកសារទាំងអស់នោះមកតម្កល់ទុក ប្រសិនបើខ្មែរក្រោមប្រគល់ទៅឲ្យរាជបណ្ឌិត្យសភាកម្ពុជា។ លោកថា គេអាចប្រើឯកសារទាំងនេះធ្វើជាឯកសារយោង សម្រាប់បម្រើដល់ការសិក្សាស្រាវជ្រាវជាបន្តបន្ទាប់ទៀត៖ «យើងត្រូវបណ្ដុះបណ្ដាលប្រវត្តិសាស្ត្រ រឿងប្រវត្តិសាស្ត្រជារឿងប្រវត្តិសាស្ត្រ យើងត្រូវតែដឹងឯកសារសម្រាប់ប្រវត្តិសាស្ត្រ ខ្មែរត្រូវតែដឹង កុំឲ្យយើងនាំគ្នាបន្តបាត់ដីទៀត។ ខ្ញុំជឿថាវាមានសារសំខាន់»។

លោកបណ្ឌិត សុខ ទូច មានប្រសាសន៍ថា មូលដ្ឋានចំណេះដឹងប្រវត្តិសាស្ត្ររបស់ពលរដ្ឋខ្មែរ ជាពិសេស គឺយុវជន នៅមានភាពទន់ខ្សោយនៅឡើយ។

ចំពោះគម្រោងស្នើសុំបញ្ចូលប្រវត្តិសាស្ត្រកម្ពុជាក្រោម ទៅក្នុងកម្មវិធីសិក្សារបស់ក្រសួងអប់រំ វិញ អ្នកនាំពាក្យក្រសួងអប់រំ យុវជន និងកីឡា លោក រស់ សាលីន ឆ្លើយតបថា រាល់ការស្នើផ្សេងៗ ក្រសួងនឹងពិនិត្យមើលទៅលើគោលការណ៍គរុកោសល្យជាមូលដ្ឋាន ថាតើវាចាំបាច់សម្រាប់សិស្សានុសិស្សយល់ដឹងពីកម្រិតមួយទៅកម្រិតមួយ ឬក៏វាមានការផ្សារភ្ជាប់គ្នាតាំងពីកម្រិតទាបរហូតដល់កម្រិតខ្ពស់ឬទេ? យ៉ាងណា លោកថាមានចំណេះដឹងផ្សេងទៀត ដែលអ្នកសិក្សាអាចសិក្សាស្រាវជ្រាវស្វែងយល់ដោយខ្លួនឯងបាន តាមរយៈព្រឹត្តិបត្រតាមរយៈសៀវភៅ ឬព័ត៌មានជាទូទៅនៅខាងក្រៅ៖ «ចំណុចសំខាន់នៅក្នុងកម្មវិធីសិក្សា គឺយើងមិនអាចដាក់គ្រប់ទិដ្ឋភាពបានទេ យើងត្រូវដាក់នូវមុខវិជ្ជាណាដែលជាមុខវិជ្ជា ដែលកំណត់តាមក្រឹត្យក្រមគរុកោសល្យដែលត្រូវបញ្ចូល។ ដូច្នេះហើយ ក្រសួងមានអនុគណៈកម្មការរៀបចំកម្មវិធីសិក្សារបស់ក្រសួង គឺពិនិត្យមើលលើទិដ្ឋភាពទាំងអស់នេះ»។

បើទោះជាកម្ពុជាក្រោម ជាអតីតទឹកដីដ៏ធំរបស់ខ្មែរក្តី ប៉ុន្តែរហូតមកទល់ពេលនេះ នៅមានពលរដ្ឋខ្មែរមួយចំនួនមិនទាន់ស្គាល់កម្ពុជាក្រោម ច្បាស់នៅឡើយ ខ្លះនៅមិនទាន់ទាំងដឹងថា តើទឹកដីកម្ពុជាក្រោម នៅកន្លែងណា ឬលាតសន្ធឹងពីណាដល់ណាឡើយ?

លោក ថាច់ សេដ្ឋា មានប្រសាសន៍ថា លោកចង់ឲ្យសិស្សនិស្សិតខ្មែរដែលជាទំពាំងស្នងឫស្សី ដឹងពីប្រវត្តិសាស្ត្ររបស់កម្ពុជាក្រោម ពិសេសប្រវត្តិសាស្ត្រដែលកម្ពុជា បាត់បង់ទឹកដីទៅប្រទេសជិតខាង ដើម្បីអាចឲ្យពួកគេរៀនសូត្រពីប្រវត្តិសាស្ត្រ និងចេះនាំគ្នាការពារទឹកដីដែលនៅសេសសល់ឲ្យបានគង់វង្ស កុំឲ្យជាន់ដានប្រវត្តិសាស្ត្របន្តទៀត៕